





# ភាពជាឪពុក

# ការបង្កើតឱ្យមានភាពជាឪពុកសំរាប់លោកអ្នកហើយនិងកូនរបស់លោកអ្នក

## តើភាពជាឪពុកគឺជាអ្វី?

ភាពជាឪពុកគឺមានន័យថា ការជាឪពុកនៃក្មេង ។ ការបង្កើតឱ្យមានឡើងភាពជាឪពុក គឺជាដំណើរការតាមផ្លូវច្បាប់មួយដើម្បីកំណត់ថាអ្នកណាគឺ ជាឪពុកបង្កើតរបស់ក្មេង ។ នៅពេលដែលឪពុកម្តាយបានរៀបអាពាហ៍ពិពាហ៍ ជាធម្មតាភាពជាឪពុកត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិ ។ បើសិនជាឪពុកម្តាយមិនបានរៀបអាពាហ៍ពិពាហ៍ទេ ការបង្កើតឱ្យមានភាពជាឪពុកមិនបានកើតឡើងដោយស្វ័យប្រវត្តិទេ ហើយឪពុកម្តាយទាំង ពីរនាក់គួរតែបង្កើតដំណើរការមួយឡើងឱ្យបានយ៉ាងឆាប់តាមលទ្ធភាពដើម្បីជាផលប្រយោជន៍កូន ។ ដោយការមិនបានបង្កើតឱ្យមានឡើងភាពជាឪពុក ឪពុកមិនមានសិទ្ធិតាមផ្លូវច្បាប់ ឬការទទួលខុសត្រូវតាមផ្លូវច្បាប់ជាឪពុកឡើយ ។ ការបង្កើតឱ្យមានឡើងភាពជាឪពុកគឺជាការចាំបាច់នៅមុនពេលដែលភាពជាអ្នកអាណាព្យាបាល ការមកសួរសុខទុក្ខ និងការជួយផ្គត់ផ្គង់កូនអាចត្រូវបានបញ្ជាឱ្យបង់ដោយតុលាការ ។ ការបង្កើតឱ្យមានឡើងភាពជាឪពុកអនុញ្ញាតឱ្យឪពុកដែលមិន បានរៀបការមានឈ្មោះរបស់ គាត់នៅលើសំបុត្រកំណើត ។ ភាពជាឪពុកអាចត្រូវបានបង្កើតឡើងដោយ ការចុះហត្ថលេខានៅលើសំណៅ *សេចក្តីប្រកាសនៃភាពជាឪពុក* ឬការឡើងតុលាការ ។ បើសិនជាឪពុកបានជាប់ទាក់ទងជាមួយកូនរបស់គាត់ចាប់តាំងពីពេលដំបូងនៃជីវិតរបស់កូន គាត់ប្រហែលជាបន្តថែរក្សាទាំងផ្នែកប្រាក់កាសនិងផ្នែកផ្លូវចិត្តសំរាប់កូន នៅពេលកូនធំចំរើនឡើង ។

PATERNITY
OPPORTUNITY
PROGRAM

## តើសេចក្តីប្រកាសនៃភាពជាឪពុកគឺជាអ្វី?

*សេចក្តីប្រកាសនៃភាពជាឪពុក*គឺជាសំណៅតាមផ្លូវច្បាប់មួយដែលថ្លែងថា បុរសនោះគឺជាឪពុកតាមច្បាប់ នៅពេលដែលបានចុះហត្ថលេខាដោយឪពុកនិងម្តាយទាំងពីរនាក់ ។ ការចុះហត្ថលេខានៅលើសំណៅនឹងបង្កើតតាមផ្លូវច្បាប់ថា បុរសនោះគឺជាឪពុកនៃក្មេងដោយមិនបាច់ទៅឡើងតុលាការ ។ ការចុះហត្ថលេខានៅលើសំណៅអនុញ្ញាតឱ្យគេចុះឈ្មោះឪពុកដែលមិនបានរៀបការនៅលើសំបុត្រកំណើតនៃកូនរបស់គាត់ ។ ការចុះហត្ថលេខានៅលើ*សេចក្តីប្រកាសនៃភាពជាឪពុក*គឺជាការស្ម័គ្រចិត្ត ។

## តើខ្ញុំអាចទទួលសំណៅសេចក្តីប្រកាសនៃភាពជាឪពុកពីកន្លែងណា?

លោកអ្នកអាចទទួលសំណៅ*សេចក្តីប្រកាសនៃភាពជាឪពុក*នៅឯមន្ទីរពេទ្យ ឬគិលានដ្ឋានបន្ទាប់ពីកូនរបស់លោកអ្នកបានកើតមក ។ ការចុះហត្ថលេខានៅមន្ទីរពេទ្យ គឺជាវិធីលឿន ងាយស្រួល និងមិនអស់ប្រាក់ដើម្បីឱ្យឈ្មោះរបស់ឪពុកបញ្ចូលទៅក្នុងសំបុត្រកំណើតនៃកូនរបស់គាត់ ។ ការិយាល័យចុះឈ្មោះកំណើតនិងស្លាប់នៅក្នុងតំបន់របស់លោកអ្នក ការិយាល័យផ្គត់ផ្គង់គ្រួសារនៃខណ្ឌ ការិយាល័យសម្របសម្រួលច្បាប់គ្រួសារ ឬការិយាល័យសុខុមាលភាពក៏អាចផ្តល់សំណៅ*សេចក្តីប្រកាសនៃភាពជាឪពុក*មួយច្បាប់ជូនលោកអ្នកដែរ ។ បើសិនជាលោកអ្នកជ្រើសរើសបំពេញ និងចុះហត្ថលេខានៅលើសំណៅ*សេចក្តីប្រកាសនៃភាពជាឪពុក*បន្ទាប់ពីចេញពីមន្ទីរពេទ្យ លោកអ្នកនឹងត្រូវបង់ប្រាក់ឈ្នួលទៅឱ្យការិយាល័យរដ្ឋផ្នែកបញ្ជីអត្រានុកូលដ្ឋានដើម្បីឱ្យគេបញ្ចូលឈ្មោះឪពុកទៅក្នុងសំបុត្រកំណើត ។


**State of California** *(រដ្ឋកាលីហ្វរ័នីញ៉ា)*
Arnold Schwarzenegger, អភិបាលរដ្ឋ

**Health and Human Services Agency**
*(ក្រសួងសុខភាពនិងមនុស្សភាព)*
S. Kimberly Belshé, លេខាធិការរដ្ឋ

**California Department of Social Services**
*(ក្រសួងសង្គមកិច្ចរដ្ឋកាលីហ្វរ័នីញ៉ា)*

PUB 244 (CB) (1/04)


**ការិយាល័យឱ្យប្រតិបត្តិតាមក្នុងការបង់ប្រាក់ជួយផ្គត់ផ្គង់កូន (Child Support Enforcement Office) របស់លោកអ្នក :**

បើសិនជាមិនមានបោះត្រានៅខាងក្រោមនេះទេ សូមស្វែងរកនៅក្នុងសៀវភៅទូរស័ព្ទនៅក្រោមចំណងជើងការិយាល័យមេធាវីតំបន់ (District Attorney's Office) ។





# ការមានឱកាសដ៏ល្អ

# សិទ្ធិហើយនិងផលប្រយោជន៍នានា





# សេចក្តីស្រឡាញ់



### តើសេចក្តីប្រកាសនៃភាពជាឪពុកអាចជួយចំពោះលោកអ្នករបៀបណា?

នៅពេលឪពុកម្តាយនៃក្មេងមិនបានរៀបការនៅពេលចាប់ផ្តើមនៃការមានផ្ទៃពោះ ឬនៅពេលកំណើតនៃកូន ឪពុកមិនត្រូវបានគេចាត់ថាជាឪពុកពេញច្បាប់ដោយមានសិទ្ធិ និងការទទួលខុសត្រូវចំពោះកូនឡើយ ។ ដើម្បីជួយឱ្យទទួលនូវសិទ្ធិតាមច្បាប់ជាឪពុកនៃក្មេង អ្នកជាឪពុកអាចចុះហត្ថលេខានៅលើសំណៅ*សេចក្តីប្រកាសនៃភាពជាឪពុក(Declaration of Paternity)* ។ សំណៅនេះនឹងបង្កើតជាទំនាក់ទំនងតាមផ្លូវច្បាប់រវាងឪពុក ហើយនិងកូនដោយមិនចាំបាច់ឡើងតុលាការ ។

### តើកូនទទួលផលប្រយោជន៍របៀបណា...

ដោយការបង្កើតឱ្យមានភាពជាឪពុក កូនទទួលនូវសិទ្ធិនិងផលប្រយោជន៍តាមផ្លូវច្បាប់ជាកូនដែលបានកើតមកដោយឪពុកម្តាយបានរៀបការ ។ សិទ្ធិនិងផលប្រយោជន៍ទាំងនោះអាចមានគិតបញ្ចូលទាំង :

- ការជួយផ្គត់ផ្គង់ពីឪពុកនិងម្តាយទាំងពីរនាក់
- ឯកសារតាមផ្លូវច្បាប់អំពីឪពុកម្តាយរបស់ក្មេងគឺជាអ្នកណា
- ចូលពិនិត្យមើលកំណត់ហេតុផ្នែកពេទ្យនៃគ្រួសារ
- ការធានារ៉ាប់រងសុខភាពនិងផ្នែកជីវិតពីឪពុកឬម្តាយ បើមាន
- កិច្ចការពារកេរ្តិ៍មរតក
- ជំនួយសន្តិសុខសង្គ្រោះ និងអតីតយុទ្ធជន បើមាន
- ផលប្រយោជន៍ផ្នែកផ្លូវចិត្តដោយការដឹងថា ឪពុកម្តាយទាំងពីរនាក់គឺជាអ្នកណា

### តើឪពុកទទួលផលប្រយោជន៍របៀបណា...

ការបង្កើតឱ្យមានភាពជាឪពុកអាចជួយឪពុកឱ្យមានការពិសោធន៍នូវភាពរស់នៅជាមួយគ្នា និងអំណោយផ្នែកផ្លូវចិត្តដែលកើតឡើងដោយសារតែការចំណាយពេលវេលាជាមួយកូនរបស់គាត់ ។ គាត់អាចសប្បាយរីករាយនូវផលប្រយោជន៍នៃភាពជាឪពុកដែលមានគិតបញ្ចូលទាំង :

- ការបង្កើតឱ្យមានតាមផ្លូវច្បាប់នូវសិទ្ធិ និងការទទួលខុសត្រូវនៃការជាឪពុក
- មានឈ្មោះរបស់គាត់បញ្ចូលទៅលើសំបុត្រកំណើតរបស់ក្មេង
- មានឱកាសប្រើនាមត្រកូលរបស់គាត់ដាក់ឈ្មោះឱ្យកូន បើសិនជាទាំងឪពុកទាំងម្តាយជ្រើសរើស
- ការអាចបញ្ចូលឈ្មោះកូនទៅក្នុងគ្រោងការធានារ៉ាប់រងសុខភាពរបស់គាត់
- ធានាអះអាងថា ជំនួយសន្តិសុខសង្គ្រោះ ឬអតីតយុទ្ធជនបានបង់ទៅឱ្យកូននៅក្នុងករណីដែលគាត់ស្លាប់ឬពិការ បើសិនជាមានសិទ្ធិទទួល
- ការពារនូវសិទ្ធិកូនរបស់គាត់ក្នុងការទទួលកេរ្តិ៍មរតកពីឪពុក
- សិទ្ធិក្នុងការស្វែងរកភាពជាអ្នកអាណាព្យាបាល ឬការមកសួរសុខទុក្ខតាមបណ្តឹងតុលាការ និងដើម្បីពិភាក្សាអំពីការទុកដាក់កូនឱ្យគេចិញ្ចឹម

### តើម្តាយទទួលផលប្រយោជន៍របៀបណា...

ការបង្កើតឱ្យមានភាពជាឪពុកអាចជួយចំពោះម្តាយ ដោយការចែករំលែកនូវបន្ទុកផ្នែកប្រាក់កាស និងការគាបសង្កត់ផ្នែកផ្លូវចិត្តដែលឪពុកឬម្តាយរស់នៅតែឯងពេបប្រទះ ។ ដោយការរួមសហការរបស់ឪពុកម្តាយអាចផ្តល់នូវការគាំទ្រផ្នែកផ្លូវចិត្តយ៉ាងធំមួយចំពោះ ម្តាយឪពុក ហើយនិងកូន ។ ម្តាយក៏អាចមានការរីករាយជាមួយនឹងផលប្រយោជន៍នៃភាពជាឪពុកដែរដែលមានបញ្ចូល :

- បង្កើននូវសន្តិសុខផ្នែកប្រាក់កាសសំរាប់គ្រួសារ
- ពត៌មានអំពីប្រវត្តិផ្នែកពេទ្យនៃគ្រួសារ
- ជួយក្នុងការចែករំលែកនូវការទទួលខុសត្រូវនៃឪពុកម្តាយ
- ទទួលនូវការធានារ៉ាប់រងផ្នែកពេទ្យសំរាប់កូន បើសិនជាមាន ។

### *តើខ្ញុំអាចបោះបង់ចោលឬទុកជាមោឃៈនូវសេចក្តីប្រកាសនៃភាពជាឪពុកបន្ទាប់ពីខ្ញុំបានចុះហត្ថលេខារួចមក?*

ឪពុកឬម្តាយអាចលុបចោលនូវ*សេចក្តីប្រកាសនៃភាពជាឪពុក*បានដោយបំពេញសំណៅ*ទុកជាមោឃៈនូវភាពជាឪពុក (Rescission of Paternity)* ។ សំណៅនេះត្រូវតែបានបំពេញជាមួយនិងក្រសួងសង្គមកិច្ចនៃរដ្ឋកាលីហ្វ័រនីញ៉ានៅ ក្នុងរវាង៦០ថ្ងៃនៃកាលបរិច្ឆេទសេចក្តីប្រកាសនៃភាពជាឪពុកត្រូវបានចុះហត្ថលេខា ។ លោកអ្នកគួរតែផ្ញើទៅ :

California Department of Social Services
Attention: POP Unit
C/O Data Image Systems
3062 Prospect Park Drive,
Suite A
Sacramento, CA 95670

សណៅនេះមាននៅការិយាល័យជួយផ្គត់ផ្គង់ គ្រួសារនៃមេធាវីតំបន់ (District Attorney’s Family Support Office) ឬការិយាល័យចុះ ឈ្មោះកំណើត និងស្លាប់នៅក្នុងតំបន់ ។

### តើខ្ញុំត្រូវទៅទីណា បើសិនជាខ្ញុំមានសំណួរបន្ថែម

សំរាប់ពត៌មានបន្ថែម អំពី*សេចក្តីប្រកាសនៃភាពជាឪពុក* ការបង្កើតឱ្យមាននូវការជួយផ្គត់ផ្គង់ចំពោះឪពុកម្តាយឬកូន សូមទាក់ទងជាមួយការិយាល័យជួយផ្គត់ផ្គង់គ្រួសារនៃមេធាវីតំបន់ក្នុងតំបន់របស់លោកអ្នក ឬអង្គការផ្តល់ជំនួយផ្នែកច្បាប់ ។

# ការគាំទ្រផ្នែកផ្លូវចិត្ត

